**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ទីស្តីការគណៈរដ្ឋមន្ត្រី

លេខ ៩៥៦ សជណ

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**ជម្រាបជូន**

**-ឯកឧត្តម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**-ឯឧត្តម រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**-ឯកឧត្តម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**-ឯកឧត្តម អភិបាល នៃគណៈអភិបាលខេត្តរតនគិរី**

**-ឯកឧត្តម អភិបាល នៃគណៈអភិបាលខេត្តឧត្តរមានជ័យ**

**-ឯកឧត្តម អភិបាល នៃគណៈអភិបាលខេត្តព្រះវិហារ**

**-ឯកឧត្តម អភិបាល នៃគណៈអភិបាលខេត្តក្រចេះ**

**-ឯកឧត្តម អភិបាល នៃគណៈអភិបាលខេត្តកំពង់ស្ពឺ**

**កម្មវត្ថុ ៖** របាយការណ៍ស្តីពីលទ្ធផល នៃកិច្ចប្រជុំរបស់គណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ចចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥។

**យោង ៖** -របាយការណ៍ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ របស់គណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច

-ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ២០១៥។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូន **ឯកឧត្តម** ជ្រាបថា៖ ចំពោះរបាយការណ៍របស់គណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ទាក់ទងនឹងការវាយតម្លៃក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន **១៥** ក្រុមហ៊ុន ស្ថិតក្នុងខេត្តរតនគិរី ខេត្តឧត្តរមានជ័យ ខេត្តព្រះវិហារ ខេត្តក្រចេះ និងខេត្តកំពង់ស្ពឺ រាជរដ្ឋាភិបាលសម្រេចដូចខាងក្រោម៖

I-ខេត្តរតនគិរី

**១-ក្រុមហ៊ុន នុភាព សុភី អ៊ិនវេសមេន** (NOUPHEAP SOPHY INVESTMENT Co.,Ltd) ៖

១- អនុញ្ញាតឱ្យក្រុមហ៊ុន **នុភាព សុភី អ៊ិនវេសមេន** (NOUPHEAP SOPHY INVESTMENT Co.,Ltd) ដែលមានទីតាំងស្ថិតនៅតំបន់ប្រើប្រាស់ដោយចីរភាព នៃឧទ្យានជាតិវីរៈជ័យ ក្នុងភូមិសាស្ត្រស្រុកតាវែង និងស្រុកអណ្តូងមាស ខេត្តរតនគិរី បន្តនីតិវិធីដោយទុករយៈពេល **០៦ (ប្រាំមួយ) ខែ** ដើម្បីតាមដានវឌ្ឍនភាព និងកែសម្រួលរយៈពេលវិនិយោគពី **៧០ (ចិតសិប) ឆ្នាំ** មកជា **៥០ (ហាសិប) ឆ្នាំ**។

២- ប្រគល់ជូនក្រសួងបរិស្ថាន និងអាជ្ញាធរខេត្តរតនគិរី ត្រួតពិនិត្យ តាមដានអំពីវឌ្ឍនភាពរបស់ក្រុមហ៊ុននេះឱ្យបានហ្មត់ចត់បំផុត។ ក្នុងករណីដែលក្រុមហ៊ុនមិនបានអនុវត្តត្រឹមត្រូវក្នុងរយៈពេលកំណត់ខាងលើ ក្រសួងបរិស្ថានត្រូវរាយការណ៍ជូនគណៈកម្មការអន្តរក្រសួងដើម្បីមានវិធានការ។

**២-ក្រុមហ៊ុន ស្រ៊ុន សុវណ្ណភូមិ អ៊ិនវេសមេន** (SRUN SOVANNAPHOUM INVESTMENT Co.,Ltd) ៖

១- អនុញ្ញាតឲ្យក្រុមហ៊ុន **ស្រ៊ុន សុវណ្ណភូមិ អ៊ិនវេសមេន** (SRUN SOVANNAPHOUM INVESTMENT Co.,Ltd) ដែលមានទីតាំងស្ថិតនៅតំបន់ប្រើប្រាស់ដោយចីរភាព នៃឧទ្យានជាតិវីរៈជ័យ ក្នុងភូមិសាស្ត្រស្រុកតាវែង ខេត្តរតនគិរី បន្តនីតិវិធីដោយទុករយៈពេល **០៦ (ប្រាំមួយ) ខែ** ដើម្បីតាមដានវឌ្ឍនភាព និងកែសម្រួលរយៈពេលវិនិយោគពី **៧០ (ចិតសិប) ឆ្នាំ** មកជា **៥០ (ហាសិប) ឆ្នាំ**។

២-ប្រគល់ជូនក្រសួងបរិស្ថាន និងអាជ្ញាធរខេត្តរតនគិរី ត្រួតពិនិត្យ តាមដានអំពីវឌ្ឍនភាពរបស់ក្រុមហ៊ុននេះឲ្យបានហ្មត់ចត់បំផុត។ ក្នុងករណីដែលក្រុមហ៊ុនមិនបានអនុវត្តត្រឹមត្រូវក្នុងរយៈពេលកំណត់ខាងលើ ក្រសួងបរិស្ថានត្រូវរាយការណ៍ជូនគណៈកម្មការអន្តរក្រសួងដើម្បីមានវិធានការ។

II-ខេត្តឧត្តរមានជ័យ

**១-ក្រុមហ៊ុន ដាតា រ៉ាប់ប៊ើរ (ខេមបូឌា)** (DATA RUBBER (CAMBODIA) CO., LTD) ៖

១-អនុញ្ញាតឲ្យក្រុមហ៊ុន **ដាតា រ៉ាប់ប៊ើរ (ខេមបូឌា)** (DATA RUBBER (CAMBODIA) CO., LTD) ដែលមានទីតាំងស្ថិតនៅក្នុងដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ភូមិសាស្ត្រស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ បន្តនីតិវិធីលើផ្ទៃដីដែលបានដោះស្រាយផលប៉ះពាល់រួច ដោយចុះកិច្ចសន្យាឡើងវិញ និងកែសម្រួលរយៈពេលវិនិយោគពី **៧០ (ចិតសិប) ឆ្នាំ** មកជា **៥០ (ហាសិប) ឆ្នាំ**។

២-ប្រគល់ភារកិច្ចជូនក្រសួងបរិស្ថាន អាជ្ញាធរខេត្តឧត្តរមានជ័យ និងស្ថាប័នពាក់ព័ន្ធកំណត់ព្រំប្រទល់ដី **(បញ្ជាក់និយាមកា)** គម្រោងវិនិយោគដីសម្បទានក្រុមហ៊ុន **ដាតា រ៉ាប់ប៊ើរ (ខេមបូឌា)** (DATA RUBBER (CAMBODIA) CO., LTD) ឡើងវិញឲ្យបានច្បាស់លាស់ ដោយជំរុញការចុះបញ្ជីដីរដ្ឋ ការអនុវត្តកិច្ចសន្យា និងផែនការមេឱ្យបានហ្មត់ចត់។

៣- កែសម្រួលអនុក្រឹត្យលេខ **១១២.អនក្រ.បក** ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១១ របស់រាជរដ្ឋាភិបាល ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព និង អនុក្រឹត្យលេខ **១៦៨.អនក្រ.បក** ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ របស់រាជរដ្ឋាភិបាល ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ **៧.៧០០ (ប្រាំពីរពាន់ប្រាំពីររយ) ហិកតា** ក្នុងដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ស្ថិតនៅក្នុងភូមិសាស្ត្រស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

៤- ប្រគល់ផ្ទៃដីកាត់ចេញទាំងអស់ជូនក្រសួងបរិស្ថាន និងអាជ្ញាធរខេត្តឧត្តរមានជ័យគ្រប់គ្រង។

៥- ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងបរិស្ថាន និងអាជ្ញាធរខេត្ត រៀបចំបែបបទបច្ចេកទេស គ្រប់គ្រងផ្ទៃដីដែលមានផលប៉ះពាល់ស្របតាមលិខិតបទដ្ឋានជាធរមាន។

**២-ក្រុមហ៊ុន លន់ អេហ្គ្រីថេក អ៊ិនវេសមេន ខមភេនី** (LUN Agritech Investment Company Ltd) ៖

១- អនុញ្ញាតឲ្យក្រុមហ៊ុន លន់ អេហ្គ្រីថេក អ៊ិនវេសមេន ខមភេនី (LUN Agritech Investment Company Ltd) ដែលមានទីតាំងស្ថិតនៅក្នុងតំបន់ដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ភូមិសាស្ត្រខេត្តឧត្តរមានជ័យ និងខេត្តព្រះវិហារ បន្តនីតិវិធីលើផ្ទៃដីដែលបានដោះស្រាយផលប៉ះពាល់រួច និងកែសម្រួលរយៈពេលវិនិយោគពី **៧០ (ចិតសិប) ឆ្នាំ** មកជា **៥០ (ហាសិប) ឆ្នាំ**។

២- ប្រគល់ភារកិច្ចជូនក្រសួងបរិស្ថាន អាជ្ញាធរខេត្តឧត្តរមានជ័យ និងខេត្តព្រះវិហារ និងស្ថាប័នពាក់ព័ន្ធកំណត់ព្រំប្រទល់ដី **(បញ្ជាក់និយាមកា)** គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន **លន់ អេហ្គ្រីថេក អ៊ិនវេសមេន ខមភេនី (LUN Agritech Investment Company Ltd)** ឡើងវិញឲ្យបានច្បាស់លាស់ ដោយជំរុញការចុះបញ្ជីដីរដ្ឋ ការចុះកិច្ចសន្យា និងធ្វើផែនការមេឱ្យបានឆាប់។

៣-កែសម្រួលអនុក្រឹត្យលេខ **៥២.អនក្រ.បក** ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១២ របស់រាជរដ្ឋាភិបាល ស្តីពីការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព និងអនុក្រឹត្យលេខ **៨៦.អនក្រ.បក** ចុះថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១២ របស់រាជរដ្ឋាភិបាល ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ **៤.០៩៥ (បួនពាន់កៅសិបប្រាំ) ហិកតា** ក្នុងតំបន់ដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តឧត្តរមានជ័យ និងខេត្តព្រះវិហារ។

៤- ប្រគល់ផ្ទៃដីកាត់ចេញទាំងអស់ជូនក្រសួងបរិស្ថាន អាជ្ញាធរខេត្តឧត្តរមានជ័យ និងខេត្តព្រះវិហារគ្រប់គ្រង។

៥- ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងបរិស្ថាន និងអាជ្ញាធរខេត្ត រៀបចំបែបបទបច្ចេកទេស គ្រប់គ្រងផ្ទៃដីដែលមានផលប៉ះពាល់ស្របតាមលិខិតបទដ្ឋានជាធរមាន។

**៣-ក្រុមហ៊ុន** Nature Plantation (K.H) Co.,Ltd ៖

១- អនុញ្ញាតឲ្យក្រុមហ៊ុន Nature Plantation (K.H) Co.,Ltd ដែលមានទីតាំងស្ថិតនៅក្នុងដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ក្នុងភូមិសាស្ត្រ ខេត្តឧត្តរមានជ័យ បន្តនីតិវិធីលើផ្ទៃដីដែលបានដោះស្រាយផលប៉ះពាល់រួច និងកែសម្រួលរយៈពេលវិនិយោគពី **៧០ (ចិតសិប) ឆ្នាំ** មកជា **៥០ (ហាសិប) ឆ្នាំ**។

២- ប្រគល់ភារកិច្ចជូនក្រសួងបរិស្ថាន អាជ្ញាធរខេត្តឧត្តរមានជ័យ និងស្ថាប័នពាក់ព័ន្ធកំណត់ព្រំប្រទល់ដី **(បញ្ជាក់និយាមកា)** គម្រោងវិនិយោគដីសម្បទានក្រុមហ៊ុន Nature Plantation (K.H) Co.,Ltd ឡើងវិញឲ្យបានច្បាស់លាស់ ដោយជំរុញការចុះកិច្ចសន្យា ធ្វើផែនការមេ និងការចុះបញ្ជីដីរដ្ឋឱ្យបានឆាប់។

៣- កែសម្រួលអនុក្រឹត្យលេខ ២៧១.អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១១ របស់រាជរដ្ឋាភិបាល ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព និងអនុក្រឹត្យលេខ ០៨.អនក្រ.បក ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១២ របស់រាជរដ្ឋាភិបាល ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ ៩.០២០ (ប្រាំបួនពាន់ម្ភៃ) ហិកតា ក្នុងដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ស្ថិតនៅក្នុងភូមិសាស្រ្ត ខេត្តឧត្តរមានជ័យ។

៤- ប្រគល់ផ្ទៃដីកាត់ចេញទាំងអស់ជូនក្រសួងបរិស្ថាន និងអាជ្ញាធរខេត្តឧត្តរមានជ័យគ្រប់គ្រង។

៥- ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងបរិស្ថាន និងអាជ្ញាធរខេត្ត រៀបចំបែបបទបច្ចេកទេស គ្រប់គ្រងផ្ទៃដីដែលមានផលប៉ះពាល់ស្របតាមលិខិតបទដ្ឋានជាធរមាន។

**៤-ក្រុមហ៊ុន សេ ហុង ផ្លេនថេសិន ខមភេនី លីមីធីត** (SE HONG PLANTATION COMPANY LIMITED) ៖

១- អនុញ្ញាតឲ្យក្រុមហ៊ុន **សេ ហុង ផ្លេនថេសិន ខមភេនី លីមីធីត** (SE HONG PLANTATION COMPANY LIMITED) ដែលមានទីតាំងស្ថិតនៅក្នុងតំបន់ដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ក្នុងភូមិសាស្រ្ត ខេត្តឧត្តរមានជ័យ និងខេត្តព្រះវិហារ បន្តនីតិវិធីលើផ្ទៃដីដែលបានដោះស្រាយផលប៉ះពាល់រួចហើយចុះកិច្ចសន្យាឡើងវិញ និងកែសម្រួលរយៈពេលវិនិយោគពី **៧០ (ចិតសិប) ឆ្នាំ**មកជា **៥០ (ហាសិប) ឆ្នាំ**។

២- ប្រគល់ភារកិច្ចជូនក្រសួងបរិស្ថាន អាជ្ញាធរខេត្តឧត្តរមានជ័យ ខេត្តព្រះវិហារ និងស្ថាប័នពាក់ព័ន្ធកំណត់ព្រំប្រទល់ដី **(បញ្ជាក់និយាមកា)** គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន **សេ ហុង ផ្លេនថេសិន ខមភេនី លីមីធីត** (SE HONG PLANTATION COMPANY LIMITED) ឡើងវិញឲ្យបានច្បាស់លាស់ ដោយជំរុញការចុះបញ្ជីដីរដ្ឋ និងការអនុវត្តកិច្ចសន្យា និងផែនការមេឱ្យបានហ្មត់ចត់។

៣- កែសម្រួលអនុក្រឹត្យលេខ **៥៥.អនក្រ.បក** ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១២ របស់រាជរដ្ឋាភិបាល ស្តីពីការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព និងអនុក្រឹត្យលេខ **៨៧.អនក្រ.បក** ចុះថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១២ របស់រាជរដ្ឋាភិបាល ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ **៩.៧០០ (ប្រាំបួនពាន់ប្រាំពីររយ) ហិកតា** ក្នុងតំបន់ជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ស្ថិតនៅក្នុងភូមិសាស្រ្ត ខេត្តឧត្តរមានជ័យ និងខេត្តព្រះវិហារ។

៤- ប្រគល់ផ្ទៃដីកាត់ចេញទាំងអស់ជូនក្រសួងបរិស្ថាន អាជ្ញាធរខេត្តឧត្តរមានជ័យ និងខេត្តព្រះវិហារគ្រប់គ្រង។

៥- ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងបរិស្ថាន និងអាជ្ញាធរខេត្ត រៀបចំបែបបទបច្ចេកទេស គ្រប់គ្រងផ្ទៃដីដែលមានផលប៉ះពាល់ស្របតាមលិខិតបទដ្ឋានជាធរមាន។

**III-ខេត្តក្រចេះ**

**១-ក្រុមហ៊ុន ចំការកៅស៊ូមេមត់ ឌូអិលធីឌី ៖**

១- អនុញ្ញាតឲ្យក្រុមហ៊ុន **ចំការកៅស៊ូមេមត់ ខូអិលធីឌី** ដែលមានទីតាំងស្ថិតនៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាព នៃដែនជម្រកសត្វព្រៃស្នួល ខេត្តក្រចេះ បន្តនីតិវិធីដោយទុករយៈពេល ០១ (មួយ) ឆ្នាំ ដើម្បីតាមដានវឌ្ឍនភាព និងកែសម្រួលរយៈពេលវិនិយោគពី ៩០ (កៅសិប) ឆ្នាំ មកជា ៥០ (ហាសិប) ឆ្នាំ។

២- ប្រគល់ជូនក្រសួងបរិស្ថាន និងអាជ្ញាធរខេត្តក្រចេះ ត្រួតពិនិត្យ តាមដានអំពីវឌ្ឍនភាពរបស់ក្រុមហ៊ុននេះឲ្យបានហ្មត់ចត់បំផុត ក្នុងករណីដែលក្រុមហ៊ុនមិនបានអនុវត្តត្រឹមត្រូវក្នុងរយៈពេលកំណត់ខាងលើក្រសួងបរិស្ថានត្រូវរាយការណ៍ជូនគណៈកម្មការអន្តរក្រសួងដើម្បីមានវិធានការ។

## ២-ក្រុមហ៊ុន សុវណ្ណ រុទ្ធី ខូ អិលធីឌី៖

១- អនុញ្ញាតឲ្យក្រុមហ៊ុន **សុវណ្ណ វុទ្ធី ខូ អិលធីឌី** ស្ថិតក្នុងភូមិសាស្ត្រ ឃុំ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ ខេត្តក្រចេះ បន្តនីតិវិធីលើផ្ទៃដីដែលបានឈូសឆាយរួចចំនួន **១.២៧៩ (មួយពាន់ពីររយចិតសិបប្រាំបួន) ហិកតា** និងកែសម្រួលរយៈពេលវិនិយោគពី **៩០ (កៅសិប) ឆ្នាំ** មកជា **៥០ (ហាសិប) ឆ្នាំ** ហើយ ចុះកិច្ចសន្យាឡើងវិញ។

២-ប្រគល់ភារកិច្ចជូនក្រសួងបរិស្ថាន អាជ្ញាធរខេត្តក្រចេះ និងស្ថាប័នពាក់ព័ន្ធកំណត់ព្រំប្រទល់ដី **(បញ្ជាក់និយាមកា)** គម្រោងវិនិយោគដីសម្បទានក្រុមហ៊ុន **សុវណ្ណ វុទ្ធី ខូ អិលធីឌី** ឡើងវិញឱ្យបានច្បាស់លាស់។

៣-កែសម្រួលអនុក្រឹត្យលេខ **១៥៤.អនក្រ.បក** ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១០ របស់រាជរដ្ឋាភិបាល ស្តីពីការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព និងអនុក្រឹត្យលេខ **៤៩.អនក្រ.បក** ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១១ របស់រាជរដ្ឋាភិបាល ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ **៥.០០០ (ប្រាំពាន់) ហិកតា** ស្ថិតក្នុងភូមិសាស្ត្រ ឃុំ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ។

៤- ប្រគល់ផ្ទៃដីកាត់ចេញទាំងអស់ជូនក្រសួងបរិស្ថាន និងអាជ្ញាធរខេត្តក្រចេះគ្រប់គ្រង។

៥- ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងបរិស្ថាន និងអាជ្ញាធរខេត្ត រៀបចំបែបបទបច្ចេកទេស គ្រប់គ្រងផ្ទៃដីដែលមានផលប៉ះពាល់ស្របតាមលិខិតបទដ្ឋានជាធរមាន។

## ៣-ក្រុមហ៊ុន ត្រាចញៀម ហ្វីហាន ដូវទី-ហ្វាតទ្រៀន ដាយណាម-កម្ពុជា៖

១- អនុញ្ញាតឲ្យក្រុមហ៊ុន **ត្រាចញៀម ហ្វីហាន ដូវទី-ហ្វាតទ្រៀន ដាយណាម-កម្ពុជា** ដែលមានទីតាំងស្ថិតនៅក្នុងតំបន់ដែនជម្រកសត្វព្រៃស្នួល ក្នុងភូមិសាស្ត្រស្រុកស្នួល ខេត្តក្រចេះ បន្តនីតិវិធីលើផ្ទៃដីដែលបានដោះស្រាយផលប៉ះពាល់រួច ហើយចុះកិច្ចសន្យាឡើងវិញ និងកែសម្រួលរយៈពេលវិនិយោគពី **៨០ (ប៉ែតសិប) ឆ្នាំ**មកជា **៥០ (ហាសិប) ឆ្នាំ**។

២-ប្រគល់ភារកិច្ចជូនក្រសួងបរិស្ថាន អាជ្ញាធរខេត្តក្រចេះ និងស្ថាប័នពាក់ព័ន្ធកំណត់ព្រំប្រទល់ដី (បញ្ជាក់និយាមកា) គម្រោងវិនិយោគដីសម្បទានក្រុមហ៊ុន **ត្រាចញៀម ហ្វីហាន ដូវទី-ហ្វាតទ្រៀន ដាយណាម-កម្ពុជា** ឡើងវិញឲ្យបានច្បាស់លាស់។

៣-កែសម្រួលអនុក្រឹត្យលេខ **១៧៣.អនក្រ.បក** ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៩ របស់រាជរដ្ឋាភិបាល ស្ដីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព និង អនុក្រឹត្យលេខ **០៦.អនក្រ.បក** ចុះថ្ងៃទី ០៨ ខែមករា ឆ្នាំ ២០១០ របស់រាជរដ្ឋាភិបាល ស្ដីពីការធ្វើអនុបយោគផ្ទៃដីទំហំ ៤.៤៦៨ (បួនពាន់បួនរយហុកសិបប្រាំបី) **ហិកតា** ក្នុងតំបន់ដែនជម្រកសត្វព្រៃស្នួល ក្នុងភូមិសាស្ត្រស្រុកស្នួល ខេត្តក្រចេះ។

៤-ប្រគល់ផ្ទៃដីកាត់ចេញទាំងអស់ជូនក្រសួងបរិស្ថាន និងអាជ្ញាធរខេត្តក្រចេះគ្រប់គ្រង។

៥- ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងបរិស្ថាន និងអាជ្ញាធរខេត្ត រៀបចំបែបបទបច្ចេកទេស គ្រប់គ្រងផ្ទៃដីដែលមានផលប៉ះពាល់ស្របតាមលិខិតបទដ្ឋានជាធរមាន។

**៤-ក្រុមហ៊ុន សាយឌុងកៅស៊ូ ឌុកឌុង ខូអិលធីឌី** (XAY DUNG CAOUTCHOUC DUC DUNG Co.,Ltd) ៖

១- អនុញ្ញាតឲ្យក្រុមហ៊ុន **សាយឌុងកៅស៊ូ ឌុកឌុង ខូអិលធីឌី** (XAY DUNG CAOUTCHOUC DUC DUNG Co.,Ltd) ដែលមានទីតាំងស្ថិតនៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាព នៃដែនជម្រកសត្វព្រៃស្នួល ភូមិសាស្ត្រស្រុកស្នួល ខេត្តក្រចេះ បន្តនីតិវិធីលើផ្ទៃដីដែលបានដោះស្រាយផលប៉ះពាល់រួច ហើយចុះកិច្ចសន្យាឡើងវិញ និងកែសម្រួលរយៈពេលវិនិយោគពី **៩០ (កៅសិប) ឆ្នាំ** មកជា **៥០ (ហាសិប) ឆ្នាំ**។

២- ប្រគល់ភារកិច្ចជូនក្រសួងបរិស្ថាន អាជ្ញាធរខេត្តក្រចេះ និងស្ថាប័នពាក់ព័ន្ធកំណត់ព្រំប្រទល់ដី **(បញ្ជាក់និយាមកា)** គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន **សាយឌុងកៅស៊ូ ឌុកឌុង ខូអិលធីឌី** (XAY DUNG CAOUTCHOUC DUC DUNG Co.,Ltd) ឡើងវិញឲ្យបានច្បាស់លាស់។

៣-ប្រគល់ផ្ទៃដីកាត់ចេញទាំងអស់ជូនក្រសួងបរិស្ថាន និងអាជ្ញាធរខេត្តក្រចេះគ្រប់គ្រង។

៤- ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងបរិស្ថាន និងអាជ្ញាធរខេត្ត រៀបចំបែបបទបច្ចេកទេសគ្រប់គ្រងផ្ទៃដីដែលមានផលប៉ះពាល់ស្របតាមលិខិតបទដ្ឋានជាធរមាន។

**៥-ក្រុមហ៊ុន** VIETNAM KAMPUCHIA ECONOMY, TRADE AND INDUSTRY COMPANY LIMITED (VKETI) CO.,LTD ៖

១- អនុញ្ញាតឲ្យក្រុមហ៊ុន VIETNAM KAMPUCHIA ECONOMY, TRADE AND INDUSTRY COMPANY LIMITED (VKETI) CO.,LTD ដែលមានទីតាំងស្ថិតនៅតំបន់ដែនជម្រកសត្វព្រៃស្នួល ភូមិសាស្ត្រស្រុកស្នួល ខេត្តក្រចេះ បន្តនីតិវិធីលើផ្ទៃដីដែលបានដោះស្រាយផលប៉ះពាល់រួច ហើយចុះកិច្ចសន្យាឡើងវិញ និងកែសម្រួលរយៈពេលវិនិយោគពី **៧០ (ចិតសិប) ឆ្នាំ** មកជា **៥០ (ហាសិប) ឆ្នាំ**។

២-ប្រគល់ភារកិច្ចជូនក្រសួងបរិស្ថាន អាជ្ញាធរខេត្តក្រចេះ និងស្ថាប័នពាក់ព័ន្ធកំណត់ព្រំប្រទល់ដី **(បញ្ជាក់និយាមកា)** គម្រោងវិនិយោគដីសម្បទានក្រុមហ៊ុន VIETNAM KAMPUCHIA ECONOMY, TRADE AND INDUSTRY COMPANY LIMITED (VKETI) CO.,LTD ឡើងវិញឲ្យបានច្បាស់លាស់។

៣- កែសម្រួលអនុក្រឹត្យលេខ **១៧៣ អនក្រ.បក** ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៩ របស់រាជរដ្ឋាភិបាល ស្ដីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព និង

អនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១០ របស់រាជរដ្ឋាភិបាល ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ ៥.០៥៤ (ប្រាំពាន់ហាសិបប្រាំបួន) ហិកតា ក្នុងតំបន់ដែនជម្រកសត្វព្រៃស្នួល ស្ថិតក្នុងភូមិសាស្ត្រ ស្រុកស្នួល ខេត្តក្រចេះ។

៤- ប្រគល់ផ្ទៃដីកាត់ចេញទាំងអស់ជូនក្រសួងបរិស្ថាន និងអាជ្ញាធរខេត្តក្រចេះគ្រប់គ្រង។

៥- ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងបរិស្ថាន និងអាជ្ញាធរខេត្ត រៀបចំបែបបទបច្ចេកទេស គ្រប់គ្រងផ្ទៃដីដែលមានផលប៉ះពាល់ស្របតាមលិខិតបទដ្ឋានជាធរមាន។

**៦-ក្រុមហ៊ុន សុវណ្ណ រាជសីហ៍ ៖**

១- អនុញ្ញាតឲ្យក្រុមហ៊ុន **សុវណ្ណ រាជសីហ៍** ដែលមានទីតាំងស្ថិតនៅក្នុងដែនជម្រកសត្វព្រៃស្នួល ភូមិសាស្ត្រ ស្រុកស្នួល ខេត្តក្រចេះ បន្តនីតិវិធីលើផ្ទៃដីដែលបានដោះស្រាយផលប៉ះពាល់រួច ហើយចុះកិច្ចសន្យាឡើងវិញ ដោយកែសម្រួលរយៈពេលវិនិយោគពី **៧០ (ចិតសិប) ឆ្នាំ** មកជា **៥០ (ហាសិប) ឆ្នាំ**។

២- ប្រគល់ភារកិច្ចជូនក្រសួងបរិស្ថាន អាជ្ញាធរខេត្តក្រចេះ និងស្ថាប័នពាក់ព័ន្ធកំណត់ព្រំប្រទល់ដី **(បញ្ជាក់និយាមកា)** គម្រោងវិនិយោគដីសម្បទានក្រុមហ៊ុន **សុវណ្ណ រាជសីហ៍** ឡើងវិញឲ្យបានច្បាស់លាស់ និងជំរុញការអនុវត្តផែនការមេឱ្យបានហ្មត់ចត់។

៣-កែសម្រួលអនុក្រឹត្យលេខ **១៧៣ អនក្រ.បក** ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៩ របស់រាជរដ្ឋាភិបាល ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព និង អនុក្រឹត្យលេខ **០៥ អនក្រ.បក** ចុះថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១០ របស់រាជរដ្ឋាភិបាល ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ **៦.៥២៥ (ប្រាំមួយពាន់ប្រាំរយម្ភៃប្រាំ) ហិកតា** ក្នុងតំបន់ដែនជម្រកសត្វព្រៃស្នួល ស្ថិតក្នុងភូមិសាស្ត្រ ស្រុកស្នួល ខេត្តក្រចេះ។

៤- ប្រគល់ផ្ទៃដីកាត់ចេញទាំងអស់ជូនក្រសួងបរិស្ថាន និងអាជ្ញាធរខេត្តក្រចេះគ្រប់គ្រង។

៥- ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងបរិស្ថាន និងអាជ្ញាធរខេត្ត រៀបចំបែបបទបច្ចេកទេស គ្រប់គ្រងផ្ទៃដីដែលមានផលប៉ះពាល់ស្របតាមលិខិតបទដ្ឋានជាធរមាន។

**៧-ក្រុមហ៊ុន សំណាងអង្គរ ឌីវេឡុបមេន អិលធីឌី ៖**

១- អនុញ្ញាតឲ្យក្រុមហ៊ុន **សំណាងអង្គរ ឌីវេឡុបមេន អិលធីឌី** ដែលមានទីតាំងស្ថិតនៅក្នុងដែនជម្រកសត្វព្រៃស្នួល ក្នុងភូមិសាស្ត្រ ឃុំ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ បន្តនីតិវិធីលើផ្ទៃដីដែលបានដោះស្រាយផលប៉ះពាល់រួច ហើយចុះកិច្ចសន្យាឡើងវិញ ដោយកែសម្រួលរយៈពេលវិនិយោគពី **៩៩ (កៅសិបប្រាំបួន) ឆ្នាំ** មកជា **៥០ (ហាសិប) ឆ្នាំ**។

២-ប្រគល់ភារកិច្ចជូនក្រសួងបរិស្ថាន អាជ្ញាធរខេត្តក្រចេះ និងស្ថាប័នពាក់ព័ន្ធកំណត់ព្រំប្រទល់ដី **(បញ្ជាក់និយាមកា)** គម្រោងវិនិយោគដីសម្បទានក្រុមហ៊ុន **សំណាងអង្គរ ឌីវេឡុបមេន អិលធីឌី** ឡើងវិញឲ្យបានច្បាស់លាស់។

៣-កែសម្រួលអនុក្រឹត្យលេខ **១២៨ អនក្រ.បក** ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០៩ របស់រាជរដ្ឋាភិបាល ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិទៅជាតំបន់ប្រើប្រាស់ដោយចីរភាព និង អនុក្រឹត្យលេខ **១៨៣ អនក្រ.បក** ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០០៩ របស់រាជរដ្ឋាភិបាល ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ **១.២២៥ (មួយពាន់ពីររយម្ភៃប្រាំ) ហិកតា** ស្ថិតក្នុងតំបន់ដែនជម្រកសត្វព្រៃស្នួល ឃុំ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ។

៤- ប្រគល់ផ្ទៃដីកាត់ចេញទាំងអស់ជូនក្រសួងបរិស្ថាន និងអាជ្ញាធរខេត្តក្រចេះគ្រប់គ្រង។

៥- ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងបរិស្ថាន និងអាជ្ញាធរខេត្ត រៀបចំបែបបទបច្ចេកទេស គ្រប់គ្រងផ្ទៃដីដែលមានផលប៉ះពាល់ស្របតាមលិខិតបទដ្ឋានជាធរមាន។

**៨-ក្រុមហ៊ុន** E-Investment (Cambodia) Co.,Ltd **៖**

១- អនុញ្ញាតឲ្យក្រុមហ៊ុន E-Investment (Cambodia) Co.,Ltd ដែលមានទីតាំងស្ថិតនៅក្នុងតំបន់ដែនជម្រកសត្វព្រៃស្នួល ឃុំ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ បន្តនីតិវិធីលើផ្ទៃដីដែលបានដោះស្រាយផលប៉ះពាល់រួច ហើយចុះកិច្ចសន្យាឡើងវិញ ដោយកែសម្រួលរយៈពេលវិនិយោគពី **៩៩ (កៅសិបប្រាំបួន) ឆ្នាំ** មកជា **៥០ (ហាសិប) ឆ្នាំ**។

២-ប្រគល់ភារកិច្ចជូនក្រសួងបរិស្ថាន អាជ្ញាធរខេត្តក្រចេះ និងស្ថាប័នពាក់ព័ន្ធកំណត់ព្រំប្រទល់ដី **(បញ្ជាក់និយាមកា)** គម្រោងវិនិយោគដីសម្បទានក្រុមហ៊ុន E-Investment (Cambodia) Co.,Ltd ឡើងវិញឲ្យបានច្បាស់លាស់។

៣-កែសម្រួលអនុក្រឹត្យលេខ **១២៨ អនក្រ.បក** ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០៩ របស់រាជរដ្ឋាភិបាល ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព និង អនុក្រឹត្យលេខ **១៨៥ អនក្រ.បក** ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ ២០០៩ របស់រាជរដ្ឋាភិបាល ស្តីពីការធ្វើអនុបយោគផ្ទៃដីទំហំ **៦.៤៥០ (ប្រាំមួយពាន់បួនរយហាសិប) ហិកតា** ស្ថិតក្នុងតំបន់ដែនជម្រកសត្វព្រៃស្នួល ឃុំ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ។

៤- ប្រគល់ផ្ទៃដីកាត់ចេញទាំងអស់ជូនក្រសួងបរិស្ថាន និងអាជ្ញាធរខេត្តក្រចេះគ្រប់គ្រង។

៥- ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងបរិស្ថាន និងអាជ្ញាធរខេត្ត រៀបចំបែបបទបច្ចេកទេស គ្រប់គ្រងផ្ទៃដីដែលមានផលប៉ះពាល់ស្របតាមលិខិតបទដ្ឋានជាធរមាន។

**IV-ខេត្តកំពង់ស្ពឺ**

**-ក្រុមហ៊ុន អភិវឌ្ឍន៍ដំណាំឧស្សាហកម្ម អ៊ុក ឃុន ៖**

១-ប្រគល់ដីដែលមានប័ណ្ណកម្មសិទ្ធិចំនួន ១.៩៥៤ (មួយពាន់ប្រាំបួនរយហាសិបបួន) ហិកតា ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអាជ្ញាធរខេត្តកំពង់ស្ពឺពិនិត្យដោះស្រាយ។ ដោយឡែកចំពោះដីវត្ត ដីសាលារៀន និងដីដែលប្រជាពលរដ្ឋរស់នៅកាន់កាប់ជាក់ស្តែង ត្រូវពិនិត្យដោះស្រាយតាមបទបញ្ជាលេខ **០១ បប** ចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១២ របស់រាជរដ្ឋាភិបាល។

២-ប្រគល់ដីរបស់ក្រុមហ៊ុនដែលរាជរដ្ឋាភិបាលសម្រេចរួចហើយតាមរយៈលិខិតលេខ **៥៧៤ សជណ** ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១២ គឺបែងចែកដីដំណាំស្វាយចន្ទីទំហំ **៥០** (ហាសិប) ហិកតា ប្រគល់អោយទៅលោក **ទាវ យីនសេង** ជនជាតិសឹង្ហបូរី ហើយប្រគល់ដីដំណាំស្វាយចន្ទីទំហំ **៥២** (ហាសិបពីរ) ហិកតា អោយទៅភាគី លោកស្រី សុខ សុភាព (នាយកក្រុមហ៊ុនដំណាំឧស្សាហកម្ម អ៊ិក យុន) សម្រាប់សម្បទានដីសេដ្ឋកិច្ច។

៣-ដីដែលបានកាន់កាប់ដោយក្រុមហ៊ុនឯកជន និងបុគ្គលមួយចំនួន នៅលើដីសម្បទានរបស់ក្រុមហ៊ុនដំណាំឧស្សាហកម្ម **អ៊ិក យុន** ដែលមានទំហំធំត្រូវផ្ទេរមកជាដីសម្បទានសេដ្ឋកិច្ច ដោយធ្វើការចុះកិច្ចសន្យាឡើងវិញជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

សេចក្ដីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម** ជ្រាប និងចាត់ចែងអនុវត្ត។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ**

**តិកវិត សំរេច**

**ចម្លងជូន៖**

-ក្រសួងមហាផ្ទៃ

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ក្រសួងធនធានទឹក និងឧតុនិយម

-ក្រសួងរ៉ែ និងថាមពល

-អង្គភាពប្រឆាំងអំពើពុករលួយ

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តម-លោកជំទាវឧបនាយករដ្ឋមន្ត្រី

-អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី

-សមាជិកគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច

-ឯកសារ-កាលប្បវត្តិ